www.nepcambodia.org

អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល | NGO Education Partnership

*A compilation of*

# Social Media Content to Promote Education Policy

School Health Policy & Inclusive Education in Kampot
Teacher Policy Action Plan in Siem Reap
Multilingual Education National Action Plan in Ratanakiri



2023

# School Health and Inclusive Education Policy




សុខភាព គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត ដែលមិនអាចកាត់ថ្លៃបាន ព្រោះថាប្រសិនបើមិនមានសុខភាពល្អទេ យើងក៏នឹងមិនអាចសម្រេចសមិទ្ធិផលអ្វីបានឡើយ។ ឧទាហរណ៍ដូចជាការសិក្សា នៅពេលដែលយើងមិនមានសុខភាពល្អ គឺជះឥទ្ធិពលដល់ការសិក្សា ធ្វើឲ្យការសិក្សាទទួលបានលទ្ធិផលសិក្សាមិនបានល្អប្រសើរ និងមិនបានទទួលបានជោគជ័យក្នុងការសិក្សា។

ALBERT EINSTEIN

មនុស្សគ្រប់រូបតែងតែមានបំណងប្រាថ្នាចង់មានសុខភាពល្អ ពីព្រោះពេលដែលមានសុខភាពល្អ នឹងរឹងមាំ តែងតែទទួលបាននូវសុភមង្គល ទាំងផ្លូវកាយ ផ្លូវចិត្ត និងរួមរស់ជាមួយអ្នកដទៃប្រកបដោយភាពចុះសម្រុងដែលជាកត្តាធ្វើឲ្យគេ ទទួលបានជោគជ័យក្នុងជីវិតរស់នៅប្រចាំថ្ងៃ ។



#អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NepCambodia
#SchoolHealthPolicy(SHP)andInclusiveSchool Policy(ISP)inKampot







#អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NepCambodia
#SchoolHealthPolicy(SHP)andInclusiveSchool Policy(ISP)inKampot

ALBERT EINSTEIN

“យន្តការច្បាប់រឹងមាំ នាំឲ្យការអនុវត្តមានប្រសិទ្ធិភាពខ្ពស់” បង្កើតយន្តការ និងអភិវឌ្ឍន៍លើក្របខណ្ឌច្បាប់ សកម្មភាពការងារគឺត្រូវបង្កើតអោយមាននូវ លិខិតបទដ្ឋានគតិយុត្តរឹងមាំនិងច្បាស់លាស់ ដើម្បីធានាបាននូវប្រសិទ្ធិភាពការងារខ្ពស់នៃការអនុវត្តន៍សុខភាពសិក្សា។សិក្សាប្រចាំក្បួរនៅបន្ទប់សុខភាពជាដើម។



តើកុមារជានរណា?
កុមារជាធនធានដែលត្រូវការ ការគាំពារពីសំណាក់មនុស្សក្នុងមជ្ឈដ្ឋានដែលគេស្ថិតនៅពីព្រោះពួកគេត្រូវបានចាត់ទុកជាបុគ្គលទន់ខ្សោយផ្នែកកាយ និងការអភិវឌ្ឍ។ កុមារត្រូវបានរស់នៅជុំគ្នាក្នុងសង្គមមួយជាមួយមនុស្សទូទៅដែលក្នុងនោះមានដូចជាយុវវ័យ មនុស្សវ័យកណ្តាល វ័យចំណាស់ និងមនុស្សគ្រប់ស្រទាប់វណ្ណៈ។







តើកុមារមានសិទ្ធិធំៗអ្វីខ្លះ?

កុមារមានសិទ្ធិធំៗចំនួន៤ គឺ
1. សិទ្ធិរស់រានមានជីវិត
2. សិទ្ធិទទួលការការពារ
3. សិទ្ធិចូលរួម
4. សិទ្ធិអភិវឌ្ឍន៍

ALBERT EINSTEIN




រីករាយទិវាកុមារអន្តរជាតិ
#អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NepCambodia
#SchoolHealthPolicy(SHP)andInclusiveSchool Policy(ISP)inKampot

កុមារគ្រប់រូបគិតចាប់តាំងពីពេលចាប់កំណើតក្នុងផ្ទៃអាយុលើស៣ខែ អាយុជីវិតរបស់កុមារមិនត្រូវបានបុគ្គលណាម្នាក់រំលោភបំពាន និងដកហូតឡើយ។ ផ្ទុយទៅវិញពួកគេត្រូវមានការរស់រានមានជីវិតដូចគេ ដូចងដែរត្រូវទទួលបានការចិញ្ចឹមបីបាច់ថែរក្សា យកចិត្តទុកដាក់ទៅលើសុខទុក្ខ មិនថាគេមានពិការភាព ឬជាកុមារអាណាថាក្តី។ កុមារទាំងអស់ត្រូវទទួលបានការការពារ និងការធានាសុវត្ថិភាពជីវិតទៅតាមលទ្ធភាពរបស់សង្គមដែលគេរស់នៅដូចៗគ្នា។







ក្រៅពីមានជីវិតរស់ហើយកុមារត្រូវមានការចូលរួមក្នុងសកម្មភាពសង្គម គឺការទទួលបានការផ្សព្វផ្សាយព័ត៌មាន ការបញ្ចេញមតិយោបល់ក្នុងសហគមន៍ និងចូលរួមទទួលយកសេវានានារបស់សង្គមដូចជា ការអប់រំ សេវាថែទាំសុខភាព សន្តិសុខ ផ្តល់អាហារ ទីជម្រកជាដើម។

ALBERT EINSTEIN




កុមារគ្រប់រូបត្រូវតែទទួលបាននូវការការពារទៅលើសិទ្ធិ ផ្នែករាងកាយ សុខភាព ទៅលើផ្លូវចិត្ត និងបញ្ញាជាដើម។ ពួកគេត្រូវទទួលបានការពារលើសន្តិសុខសុវត្ថិភាពរស់នៅដូចគ្នានិង មិនត្រូវបានទទួលរងនូវការរំលោភបំពាន ពីសំណាក់បុគ្គលដទៃ ឬសង្គមណាមួយឡើយ។

កុមារគ្រប់រូបត្រូវទទួលបានសិទ្ធិអភិវឌ្ឍន៍
កុមារត្រូវទទួលបានការអប់រំ បណ្តុះបណ្តាល ទៅលើបញ្ញាស្មារតី ចំណេះដឹង និងមេរៀនជីវិតផ្សេងៗដើម្បីឲ្យពួកគេអាច ប្រើប្រាស់ជីវិតរស់ប្រកបដោយភាពត្រឹមត្រូវ។ ពេលដែលកុមារមានការអភិវឌ្ឍផ្នែកបញ្ញា និងចិត្តគំនិត គេអាចមានការសម្រេចចិត្ត ការជ្រើសរើស ការទទួលយកនូវបរិបទឬ បទពិសោធន៍ឬ លក្ខណៈណាមួយដែលផ្តល់អោយដោយសង្គមមួយបានត្រឹមត្រូវ និងសមស្រប។







“ សុខភាពអ្នកសិក្សាផ្សារភ្ជាប់ទៅនឹងផ្លែផ្កានៃការអប់រំ “ លើកកម្ពស់ការថែទាំសុខភាពអ្នកសិក្សា និងបុគ្គលិកអប់រំ អ្នកសិក្សាគឺសំដៅដល់ អ្នកដែលកំពុងតែទទួលយកសេវាអប់រំអ្វីមួយ ដើម្បីបង្កើនចំណេះដឹងទូទៅ ចំណេះធ្វើ ឬវិជ្ជាជីវៈនានា។
រីឯបុគ្គលិកអប់រំគឺជាអ្នកដែលផ្តល់សេវាកម្មផ្នែកអប់រំ ជាអ្នកដែលធ្វើការលើការផ្តល់ចំណេះដឹង ឬជំនាញផ្សេងៗទៅអោយអ្នកសិក្សា។

ALBERT EINSTEIN

ការរើសអើងលើកុមារ
ការរើសអើងលើកុមារគឺជាការបដិសេធភាពខុសគ្នា ឬការចូលចិត្តកុមារដោយផ្អែកលើលក្ខណៈជាមូលដ្ឋានដូចជា ជាតិសាសន៍ ពណ៌សម្បុរ ប្រភពកំណើតនិង ប្រភពកន្លែងកំណើតជាដើម។



" ចំណីអាហារជាកត្តាចម្បងក្នុងការសិក្សាប្រកបដោយសុខភាពល្អ " សុវត្ថិភាពលើការផ្តល់អាហារបត្ថម្ភ អាហារូបត្ថម្ភ គឺចង់សំដៅដល់ដំណើរនៃការផ្តល់ ឬការទទួលបាននូវអាហារចាំបាច់សម្រាប់ទ្រទ្រង់សុខភាព និងការលូតលាស់។ ការងារសំខាន់គឺផ្តោតលើការរៀបចំអាហារដ្ឋាននិងកន្លែងលក់ដូរចំណីអាហារស្របតាមការណែនាំរបស់ក្រសួង, ហាមឃាត់ការលក់ដូរចំណីអាហារដែលប៉ះពាល់ដល់សុខភាពអ្នកសិក្សា, ចំណីអាហារខ្វះអនាម័យ,ចំណីអាហារដែលត្រូវបានហាមឃាត់ពិសេសលើកុមារ,និងមានការរៀបចំឱ្យមានសួនបន្លែរួមជុំនិងដំណាំតូចធំដើម្បីបង្កើនសោភ័ណ្ឌភាពបរិស្ថានសិក្សា។







« លើកកម្ពស់គុណភាព និងអនាម័យចំណីអាហារ » ជាកស្នែងការហូបជារឿងមួយដ៏សំខាន់បំផុតសម្រាប់សុខភាព បើយើងបរិភោគចំណីអាហារណាដែលខ្វះអនាម័យនឹងធ្វើឲ្យប៉ះពាល់និងផ្តល់ផលវិបាកដល់សុខភាពជាក់ជាមិនខាន។ ដើម្បីចូលរួមធានាបាន់នូវសុខភាពរបស់អ្នកសិក្សានោះ តួនាទីរបស់គ្រឹះស្ថានសិក្សានិមួយៗត្រូវយកចិត្តទុកដាក់និង តាមដានការហូបចុករបស់សិស្សឬ អ្នកសិក្សាពិសេសចំពោះកុមារ។

ALBERT EINSTEIN

អនាម័យខ្លួនប្រាណ រាងកាយមានអនាម័យល្អ សុខភាពបរវរ ការសិក្សាប្រសើរ។ ដើម្បីទទួលបាននូវសុខភាពល្អក្រៅអំពីការហូបស្អាត ផឹកស្អាត គឺពួកគេត្រូវរស់នៅស្អាតគឺការចេះថែទាំទៅលើអនាម័យផ្ទាល់ខ្លួនរបស់គេ។ ការរៀបចំខ្លួនអោយស្អាតបាត ងូតទឹកសម្អាតខ្លួនប្រាណ ឪស្សាហ៍លាងដៃ មិនលេងល្បែងដែលបង្ករភាពកខ្វក់ ថែរក្សាក្រចកខ្លួនឲ្យល្អ ស្លៀកពាក់ស្អាតមិនមានមេរោគ គឺធ្វើឲ្យខ្លួនឯងផ្ទាល់មានអារម្មណ៍ល្អ ផាសុកភាព ដែលអាចធ្វើអោយការសិក្សាគ្មានផលវិបាក។



#អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NepCambodia
#SchoolHealthPolicy(SHP)andInclusiveSchool Policy(ISP)inKampot






ការរៀបចំបន្ទប់អនាម័យ
បន្ទប់អនាម័យ ឬបន្ទប់ទឹកពិតជាសំខាន់ណាស់ ហើយមិនអាចខ្វះបានឡើយមិនថានៅតាមគេហដ្ឋានឬទីកន្លែងសាធារណៈ ជាពិសេសគឺនៅក្នុងសាលារៀនតែម្តងព្រោះគ្មាននរណាម្នាក់ដែលមិនត្រូវការប្រើប្រាស់វាឡើយ។

ALBERT EINSTEIN

ហេដ្ឋារចនាសម្ព័ន្ធសាលារៀន
ក្រៅអំពីគុណភាពសិក្សា ការគ្រប់គ្រងដែលល្អហើយនៅតាមគ្រឹះស្ថានសិក្សាឬ សាលារៀននិមួយៗត្រូវផ្តោតសំខាន់ទៅលើការថែទាំនិង រៀបចំបរិស្ថានឲ្យមានអនាម័យនិងសណ្តាប់ធ្នាប់ល្អ។



ការអនុវត្តបំណិនសុខភាព
នៅតាមគ្រឹះស្ថានសិក្សានិមួយៗត្រូវរៀបចំឲ្យ
មានកន្លែងលាងសម្អាតដៃ ជើង សម្អាត
ធ្មេញជាដើម ដើម្បីបណ្តុះឲ្យអ្នកសិក្សាមាន
ទម្លាប់រក្សាអនាម័យ និងរស់នៅស្អាត។ មាន
បន្ទប់ទឹកប្រើប្រាស់គ្រប់គ្រាន់ និងគ្រប់វេន
សិក្សា ត្រូវសម្អាតបន្ទប់ទឹកឲ្យស្អាតជានិច្ច
ដោយមានវេនផ្លាស់គ្នាសម្អាតឲ្យទៀងទាត់។







អនុវត្តន៍ការអប់រំសុខភាព ដើម្បីឲ្យអ្នកសិក្សា
យល់ដឹងកាន់តែច្រើនពីបញ្ហាសុខភាពនោះ
នៅតាមគ្រឹះស្ថានសិក្សានីមួយៗត្រូវដាក់
បញ្ចូលកម្មវិធីអប់រំសុខភាពទៅក្នុងកម្មវិធី
សិក្សារបស់សិស្សគ្រប់កម្រិត។ ដាក់បញ្ចូល
ខ្លឹមសារអប់រំសុខភាពឲ្យបានច្រើនរួមទាំង
ជំងឺឆ្លងនិងជំងឺមិនឆ្លងជាដើម ទាំសុខភាព
ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។

ALBERT EINSTEIN

ឥទ្ធិពលគ្រួសារទៅលើការសិក្សា
ជាការពិតលទ្ធផលការសិក្សារបស់កូនៗ
ទទួលបានជោគជ័យ ឬបរាជ័យនោះ
ពិតជាមានការរួមចំណែក ពីគ្រួសារ
មួយភាគធំផងដែរ។



ថែរក្សាសុខភាពផ្លូវចិត្ត
ក្រៅអំពីសុខភាពផ្លូវកាយ អ្នកសិក្សាទាំងអស់ ត្រូវយកចិត្តទុកដាក់ទៅលើសុខភាពផ្លូវចិត្តផងដែរ។ វាពិតជាមានសារៈសំខាន់ណាស់ សម្រាប់មនុស្សទូទៅជាពិសេសអ្នកសិក្សាតែម្តង។ ដែលចាំបាច់ណាស់បើអ្នកសិក្សាមានបញ្ហាផ្លូវចិត្ត ហើយ វាក៏ជះឥទ្ធិពលដល់ការសិក្សាផងដែរ។







សម្ពាធពីមជ្ឈដ្ឋានខាងក្រៅទៅលើការសិក្សា
បញ្ហាដែលអ្នកសិក្សាតែងតែជួបប្រទះ មានបីធំៗគឺ បញ្ហាពីខ្លួនឯងផ្ទាល់ បញ្ហាគ្រួសារ និងបញ្ហាសង្គម។

ALBERT EINSTEIN

ស្ថានភាពគ្រួសារនិងការសិក្សា
ចំពោះគ្រួសារនីមួយៗតែងតែមានបញ្ហារៀងៗខ្លួន គ្រួសារខ្លះមានជីវភាពទន់ខ្សោយ មិនមានលទ្ធភាពជួយជ្រោមជ្រែងដល់ការសិក្សារបស់កូនៗឬអ្នកសិក្សាបានក៏ធ្វើឲ្យពួកគេបង្ខំចិត្តបោះបង់ការសិក្សា ឬបណ្តាលឲ្យការសិក្សាធ្លាក់ចុះព្រោះថាពួកគេត្រូវមកជួយរ៉ាប់រងលើទំនួលខុសត្រូវជីវភាពគ្រួសារ ត្រូវទៅរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសាជាដើម។



ផ្តត់គំនិតគ្រួសារក្នុងការរក្សាអនាម័យ
ការថែរក្សាអនាម័យទៅលើការរស់នៅឲ្យបាន
ស្អាតវាពិតជាសំខាន់ណាស់ ហូបស្អាត ផឹកស្អាត
និងរស់នៅស្អាតគឺជាបាវចនាក្នុងការ
រស់នៅបហរកបដោយសុខភាពល្អៗ ដាក់ស្តែង
ទម្លាប់ និងឥរិយាបថក្នុងការរស់នៅទាំងឡាយ
តែងកើតចេញពីគ្រួសារជាអ្នកផ្តល់ឲ្យដំបូង
បង្អស់ អ្នកសិក្សាទាំងអស់ក៏ទទួលបានឥទ្ធិពលពី
ក្នុងគ្រួសារជាច្រើនដូចគ្នា។







ការអប់រំសុខភាពរបស់អាណាព្យាបាល
មាតាបិតា អាណាព្យាបាលត្រូវមានតួនាទី និង
ទំនួលត្រូវខ្ពស់លើអនាគតរបស់កូនៗ ក្រៅពីការ
គាំទ្រផ្នែកហិរញ្ញវត្ថុ ការលើកទឹកចិត្តហើយ មាតា
បិតាឬអ្នកអាណាព្យាបាលត្រូវចូលរួមអប់រំកូនៗ
ដោយផ្ទាល់ផងដែរជាពិសេសលើការថែរក្សាសុខ
ភាពនេះតែម្តង។

ALBERT EINSTEIN

គុណភាពរបស់បុគ្គលិកអប់រំ
ដើម្បីឲ្យការសិក្សារបស់អ្នកសិក្សាទាំងឡាយ
ទទួលបានលទ្ធផលល្អនោះគុណភាពចំណេះដឹង
ឬគុណភាពអប់រំរបស់អ្នកអប់រំ ក៏ជាកត្តាយ៉ាង
សំខាន់បំផុតផងដែរក្នុងចូលរួមចំណែក។



ការសេពគប់មិត្តភក្តិជះឥទ្ធិពលដល់ការសិក្សា ជាក់ស្តែងមិនថាអ្នកធ្វើការក្តី អ្នកសិក្សាក្តីរមែងតែងតែមានការរាប់អាន និងទំនាក់ទំនងគ្នាជាមួយអ្នកដទៃដែលជាអ្នករួមការងារឬ រួមថ្នាក់ៗ







ចំណីអាហារដែលមានសុវត្ថិភាពខ្ពស់ដល់អ្នកសិក្សាតាមគោលការណ៍សុខភាពទូទៅ ចំណីអាហារត្រូវបានចោទឡើងយ៉ាងសំខាន់បំផុត ព្រោះថាបើយើងទទួលទានចំណីអាហារដែលល្អមានគុណភាពនោះយើងនឹងទទួលបាននូវសុខភាពល្អ និងរាងកាយរឹងមាំផងដែរ។

ALBERT EINSTEIN




អប់រំបំណិនចំពោះអ្នកលក់ដូរចំណីអាហារក្នុងគ្រឹះស្ថានសិក្សា នៅតាមគ្រឹះស្ថានសិក្សានីមួយៗ តែងតែមានអ្នកលក់ដូរចំណីអាហារ ដើម្បីឲ្យសិស្សានុសិស្សទិញទទួលទាន។

ផលវិបាកចំពោះអ្នកសិក្សាពីការបរិភោគអាហារមិនត្រឹមត្រូវ ចំពោះផលប៉ះពាល់ដែលបង្កឡើងដោយសារការបរិភោគអាហារមិនត្រឹមត្រូវតាមគោលការណ៍រក្សាសុខភាព ឬតាមក្បួនអនាម័យនោះមានដូចជា ៖

- ធ្វើឲ្យសុខភាពទន់ខ្សោយ ដាយឈឺ ឬធ្លងជំងឺផ្សេងៗ
- ស្គមពេក ឬធាត់ពេកកង្វះសារជាតិជំនួយដល់ការលូតលាស់ ឬលើសជាតិខ្លាញ់
- អាហារដែលផ្ទុកមេរោគ ឬខ្វះអនាម័យ នឹងបង្កឲ្យពាគរូស្ន ឆ្លងរោគ ឈឺក្រពះពោះវៀន ជំងឺសើរស្បែកជាដើម







ក្រុមអាហារដែលត្រូវបានហាមឃាត់ក្នុងគ្រឹះស្ថានសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ និងការពារសុខភាពអ្នកសិក្សាទាំងឡាយពីផលប៉ះពាល់នៃការបរិភោគចំណីអាហារ។

ALBERT EINSTEIN

អាហារ៦ប្រភេទដែលក្រសួងបានហាមដាច់ខាតក្នុងគ្រឹះស្ថានសិក្សា ដោយសង្កេតឃើញពីផលប៉ះពាល់ដល់សុខភាពអ្នកបរិភោគចំណីអាហារ ជាពិសេសចំពោះអ្នកសិក្សា ចេះតែឈឺច្រើន មានការកើនឡើងជាបន្តបន្ទាប់គួរឲ្យព្រួយបារម្ភជាខ្លាំង ដែលជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ការសិក្សារៀនសូត្រ។



ប្បញ្ញត្តិផាកពិន័យចំពោះអាជីវករចរាចរចំណីអាហារដែលល្មើស ដោយមើលឃើញថាការអនុវត្ត ការហាមឃាត់ និងបម្រាមនានាចំពោះអ្នកចរាចរចំណីហារទៅឲ្យអ្នកបរិភោគទាំងឡាយមិនសូវ ទទួលបានគុណភាពពេញលេញនោះ ទើបក្រសួងមានសម្ថកិច្ចចាប់ផ្ដើមចាត់វិធានការណ៍ផាកពិន័យ ទៅលើជនដែលល្មើសដូចមានខាងក្រោម។



# Teacher Policy Action Plan




សូមអបអរសាទរប្អូនស្រី សាវង់ ច្រឹប( Chreub Savong )
យុវជនមកពីខេត្តសៀមរាប និងស្វាគមន៍ប្អូនក្លាយជា
យុវជនតាំពានរបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅ
រដ្ឋាភិបាល NEP។

ALBERT EINSTEIN

តើគោលនយោបាយស្តីពីគ្រូបង្រៀនមានយុទ្ធសាស្ត្រអ្វីខ្លះ?
ដើម្បីសម្រេចគោលដៅទាំងបួននៃគោលនយោបាយស្តីពីគ្រូ
បង្រៀនក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញយុទ្ធ
សាស្ត្រសំខាន់ៗចំនួន៩និងយុទ្ធសាស្ត្ររងចំនួន៣៤។



យុទ្ធសាស្ត្រទី១.កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ
យុទ្ធសាស្ត្រទី២.ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន
យុទ្ធសាស្ត្រទី៣.កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
យុទ្ធសាស្ត្រទី៤.អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
យុទ្ធសាស្ត្រទី៥.ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា







ការចូលរួមរបស់គ្រូបង្រៀនក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេពិតជាមានសារៈសំខាន់ណាស់។ គ្រូបង្រៀនត្រូវតែមានសមត្ថភាពខ្ពស់ក្នុងការបង្ហាត់បង្រៀន បណ្តុះបណ្តាល ឬផ្ទេរចំណេះដឹង និងសមត្ថភាព ទៅឱ្យសិស្សអោយបានទូទំទូលាយ ។

ALBERT EINSTEIN

តើអ្វីទៀតជាគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ? សូមជ្រើសរើសចម្លើយមួយក្នុងចំណោមចម្លើយទាំងពីរ។



តើគ្រូបង្រៀនល្អគួរមានលក្ខណៈសម្បត្តិអ្វី?
គ្រូបង្រៀនគួរមានលក្ខណៈសម្បត្តិ៖
- ចេះយកចិត្តទុកដាក់ដល់សិស្ស
- មានទំនាក់ទំនងល្អជាមួយគ្រួសារ សាលារៀន សហគមន៍







វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ សំដៅលើការបង្រៀនដែលយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរៀនសូត្រជាក់លាក់របស់ក្មេងស្រី និងក្មេងប្រុសៗ វិធីបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រទាមទារឱ្យគ្រូបង្រៀន និងនាយក នាយិកាសាលាឆ្លើយតបនឹងសមភាពៗ
# អត្ថបទនេះគឺដកស្រង់ចេញពីសៀវភៅវិធីសាស្ត្របង្រៀន និងរៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ នៃ(ក្រសួងអប់រំយុវជននិងកីឡា នៅឆ្នាំ២០២០)

វគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនផ្ដល់សារៈសំខាន់ដូចជា៖
• រក្សាភាពទាន់សម័យលើបច្ចេកទេស វិធីសាស្ត្របង្រៀន គំនិត និងយុទ្ធសាស្ត្រថ្មីៗ







គ្រូបង្រៀនអាចអភិវឌ្ឍសមត្ថភាពរបស់ខ្លួនតាមរយៈឱកាសជាច្រើនដូចជា៖
- សន្និសីទ និងសិក្ខាសាលានានា
- វគ្គបណ្ដុះបណ្ដាលដែលផ្ដល់ដោយស្ថាប័នរដ្ឋ ឯកជន ឬសង្គមស៊ីវិល។
- ចូលរួមតាមរយៈការបណ្ដុះបណ្ដាលដែលផ្ដោតលើបច្ចេកទេសពីរបៀបបង្រៀន និង វិធីសាស្ត្រក្នុងការបង្រៀន

ALBERT EINSTEIN

ហេតុអ្វីយើងត្រូវធ្វើការបញ្ជ្រាបយេនឌ័រនៅក្នុងការអប់រំ? ការបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធវិធីទាំងឡាយណា ដែលប្រើប្រាស់សម្រាប់ដោះស្រាយ នូវវិសមភាពយេនឌ័រក្នុងសង្គម។ ដូចនេះវាមានសារៈសំខាន់ណាស់ចំពោះការយល់ដឹងជាមូលដ្ឋានអំពី ការចូលរួម ការផ្ដល់នូវសិទ្ធិនិងអំណាច និងតម្រូវការនានាដោយមិនមានការរើសអើង។



គ្រូបង្រៀនមិនមែនគ្រាន់តែជាអ្នកទៅសាលា ដើម្បីបង្ហាញមេរៀន ឬផែនការដែលក្រសួងបាន កំណត់នៅក្នុងកម្មវិធីសិក្សារនោះទេ ។ ផ្ទុយ ទៅវិញ គ្រូបង្រៀនត្រូវបំពេញតួនាទីជាច្រើន ដើម្បីឱ្យការអប់រំផ្តល់ជានមនុស្សឈានទៅមុខៗ ក្នុងនាមជាគ្រូបង្រៀនមួយរូបគឺត្រូវដើរតួនាទីជា ច្រើនដូចជា ៖ គ្រូបង្រៀនគឺជាឪពុកម្តាយាយ ជា អ្នកសីក្សាស្រាវជ្រាវជាមិត្តភក្តិជាមគ្គុទេសក៍ជាទី ប្រឹក្សា ជាអ្នក ច្នៃប្រឌិត ជាអ្នកវិភាគ ជាអ្នកផ្តល់ នូវទស្សនវិស័យ ជាអ្នកវាយតម្លៃ ជាសិល្បករ និង ជាអ្នកសម្របសម្រួល។







គ្រូបង្រៀនជាតួអង្គមួយក្នុងចំណោមតួអង្គជា ច្រើនដែលអាចកំណត់អនាគតវិស័យអប់រំ។ គ្រូបង្រៀនទាំងអស់មិនថាស្ថិតក្នុងកម្រិតណា ក៏ដោយក៏សុទ្ធតែមានសារៈសំខាន់នៅក្នុងការ បង្រៀននឹងផ្តល់ចំណេះដឹងទៅកាន់សិស្សទាំងអស់ ឲ្យបានល្អនឹងពពេញទៅដោយគុណភាព។

ALBERT EINSTEIN

ភាពលម្អៀងយេនឌ័រគឺជាផ្នែកមួយដែល ទាក់ទងនិងផ្តត់គំនិតដែលញាំងឱ្យគ្រូ បង្រៀនមានភាពលម្អៀងយេនឌ័រ។ ភាព លម្អៀងយេនឌ័ររបស់គ្រូបង្រៀនមិនត្រូវ បានកត់សម្គាល់ ហើយបានបង្កជាផលវិបាក ដែលប៉ះពាល់ដល់សិស្សមួយចំនួន។



គ្រូបង្រៀនមានភារកិច្ចប្រាំយ៉ាងគឺ :
- មុនបង្រៀន (ត្រៀមមេរៀន ស្រាវជ្រាវឯកសារ
ត្រៀមនូវសំណួរចម្លើយធ្វើកិច្ចតែងការបង្រៀន
ត្រៀមសម្ភារៈឧបទេស និង ជ្រើសរើសវិធីសាស្ត្រ
តាមពេលវេលា។
-ពន្យល់ និងដឹកនាំការរៀនសូត្ររបស់សិស្ស
ដោយបង្រៀនត្រឹមត្រូវតាមកិច្ចតែងការគោរព
-ពេលវេលា និងគោលនយោបាយរដ្ឋាភិបាល
អនុវត្តតាមការណែនាំថ្នាក់លើ។



# Multilingual Education National Action Plan




#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia

ALBERT EINSTEIN

កុមារត្រូវការសិទ្ធិដាផ្ករណីកិច្ច កិច្ចគាំពារការគោរពសិទ្ធិកុមារ នឹងលុបបំបាត់ការរើសអើងចំពោះកុមារពិការ កុមារក្រីក្រ កុមារជនជាតិដើមភាគតិច នឹងប្រឹងដាច់ខាត់លើការរំលោភបំពាន ការជួញដូរ កេងប្រវញ្ច ការប្រើប្រាស់អំពើហិង្សាគ្រប់រូបភាពមកលើកុមារ ។



*#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល*
#NEPCambodia







*#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល*
#NEPCambodia

ALBERT EINSTEIN

*#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល*
#NEPCambodia



#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia







គ្រូនិងបុគ្គលិកអង្គការបាននិយាយថាពាក្យ
ខ្មែរខ្លះពិបាកប្រែជាភាសាដើមនិងគ្រូខ្លះ
ប្រកបពាក្យខ្មែរមិនច្បាស់ នាំឱ្យសិស្សរៀន
ពាក្យខ្មែរត្រឹមត្រូវ ។

ALBERT EINSTEIN

#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia



#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia







គ្រូនិងបុគ្គលិកអង្គការបាននិយាយថាពាក្យខ្មែរខ្លះពិបាកប្រែជាភាសាដើមនិងគ្រូខ្លះប្រកបពាក្យខ្មែរមិនច្បាស់ នាំឱ្យសិស្សរៀនពាក្យខ្មែរត្រឹមត្រូវ ។

ALBERT EINSTEIN

#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia



ពួកគេមានការហ្វឹកហាត់កាន់តែច្រើនក្នុងការប្រើប្រាស់ភាសាជាពិសេសគឺនៅពេលដើលខ្លួនអភិវឌ្ឍនចំណេះអក្ខរកម្មទាំងពីរភាសាហើយអាចធ្វើការប្រៀបធៀបនិងរកចំណុចខុសគ្នានៃភាសាទាំងពីរ ។







"គ្រូបង្រៀន និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងការអប់រំពហុភាសាលើកឡើងថា ពាក្យខ្មែរមួយចំនួនពិបាកបកប្រែឱ្យត្រឹមត្រូវទៅជាភាសាជនជាតិដើមភាគតិច។ គ្រូខ្លះប្រកបពាក្យខ្មែរមិនច្បាស់ នាំអោយសិស្សរៀនពាក្យខ្មែរមិនត្រឹមត្រូវ។

ALBERT EINSTEIN

បញ្ហាដែលភាសានៃការអប់រំមិនត្រូវបានប្រើនៅផ្ទះគឺជាឧបសគ្គដ៏ធំមួយក្នុងការសម្រេចបាននូវជោគជ័យផ្នែកអប់រំ។
នេះគឺដោយសារតែសិស្សមិនត្រូវបានបន្សាំខ្លួននឹងភាសាដែលបង្រៀននៅសាលា ដែលធ្វើឱ្យពួកគេមានការលំបាកក្នុងការយល់ដឹងអំពីសម្ភារៈអាន សម្ភារៈរៀន និងមេរៀន ដែលបានបង្ហាញនៅក្នុងថ្នាក់រៀន។



"ភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិច គឺជាចំណុចសំខាន់នៃភាពជោគជ័យនៃកម្មវិធីអប់រំពហុភាសា។ ហើយការបញ្ចូលធាតុចូលពីពួកគាត់នៅក្នុងកម្មវិធីនេះ និងធ្វើឱ្យ អ្នកអប់រំអាចបង្កើតកម្មវិធីសិក្សាដែលស្របតាមតម្រូវការរបស់សិស្សជនជាតិដើមភាគតិច។ ដូច្នេះហើយ សិស្សនឹងមានឱកាសកាន់តែច្រើនក្នុងការទទួលបានជោគជ័យក្នុងការសិក្សារបស់ពួកគេ។"







កង្វះមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់ ដែលបង្កការលំបាកដល់កុមារជនជាតិដើមភាគតិចនៅក្នុងតំបន់ដាច់ស្រយាលក្នុងការចូលរៀនទៀងទាត់។ ក្រៅពីនេះ អាណាព្យាបាលមួយចំនួនដែលនៅតាមជនបទ មិនបញ្ជូនកូនទៅសាលារៀន ដោយសារបញ្ហាជីវភាព ឬដោយសារពួកគេត្រូវការជំនួយពីកូនក្នុងរដូវដាំដុះ និងរដូវប្រមូលផល។

ALBERT EINSTEIN

សិស្សជនជាតិដើមភាគតិចប្រឈមមុខនឹងបញ្ហាមួយចំនួននៅពេលទទួលបានការអប់រំ។ បញ្ហាប្រឈមទាំងនេះរួមមានកង្វះទីជម្រក គ្មានសម្ភារៈសិក្សា និងបញ្ហាសុវត្ថិភាព។ បើគ្មានការដោះស្រាយបញ្ហាទាំងនេះទេ វានៅតែផ្តល់ភាពលំបាកសម្រាប់សិស្សជនជាតិដើមភាគតិចក្នុងការទទួលបានការអប់រំ និងការអភិវឌ្ឍន៍សមត្ថភាពឱ្យបានពេញលេញ។



កង្វះចំណេះដឹងនៃការអប់រំពហុភាសាក៏ជាឧបសគ្គដល់ភាពជោគជ័យក្នុងការសិក្សាសម្រាប់សិស្សជនជាតិដើមភាគតិច។ អាណាព្យាបាលនិងសហគមន៍ដែលមិនបានយល់ច្បាស់ពីកម្មវិធីអប់រំពហុភាសាតែងតែមិនអាចផ្តល់ការគាំទ្រ និងការណែនាំចាំបាច់នានា ដល់កូនរបស់ពួកគេ ដើម្បីជួយពួកគេឱ្យទទួលបានជោគជ័យក្នុងការរៀនសូត្រ។







ដើម្បីដោះស្រាយបញ្ហាគម្លាតនៃការចូលរៀនរបស់សិស្សជនជាតិដើមភាគតិចត្រូវមានវិធានការដូចជា៖

- បង្កើតសាលានៅតាមតំបន់ដាច់ស្រយាលឱ្យបានច្រើន
- លើកកម្ពស់ការយល់ដឹងដល់អាណាព្យាបាលក្នុងការបញ្ជូនកូនចុះឈ្មោះចូលឈ្មោះចូលរៀន

ALBERT EINSTEIN

អង្គការយូណេស្កូបានបញ្ជាក់ថាការរៀនសូត្រពេញមួយជីវិតគឺជាដំណើរការមួយដែលជំនាញនិងចំណេះដឹងត្រូវបានលើកកម្ពស់ដើម្បីបង្កើនសន្តិភាពនិងភាពសុខដុមរមនាក្នុងសង្គម ។



ដើម្បីធានាបានសមភាពក្នុងការចូលរៀននៅសាលាបឋមសិក្សារបស់សិស្សជនជាតិដើមភាគតិច វិធានការនានាគួរតែត្រូវបានអនុវត្តដូចជា៖

1. ពង្រឹងវិធានការនានាដើម្បីបង្កើនការចូលរៀន វត្តមានទៀងទាត់ និងរៀនចប់បឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក។







ដើម្បីបង្កើនគុណភាព និងសុខដុមនីយកម្មការអប់រំពហុភាសា ដៃគូរពាក់ព័ន្ធគួរតែធ្វើការអភិវឌ្ឍស្តង់ដារមត្តេយ្យទូទៅ។

ALBERT EINSTEIN

កង្វះសាលាមត្តេយ្យ គឺជាបញ្ហាចម្បងដែលធ្វើឲ្យការអប់រំរបស់សិស្សជនជាតិដើមភាគតិចមិនមានភាពងាយស្រួល។ នេះដោយសារតែ ការទទួលបានការអប់រំតាមរយៈភាសាដែលមិនប្រើប្រាស់នៅផ្ទះ ធ្វើឱ្យសិស្សមានការលំបាកក្នុងការយល់ដឹងអំពីអ្វីដែលកំពុងបង្រៀន។



គណៈកម្មការសាលាបានបង្ហាញឲ្យឃើញថា សិស្សជនជាតិដើមភាគតិចបានធ្វើការចុះឈ្មោះចូលរៀនច្រើនក្នុងថ្នាក់ប្រកួតភាសា,នឹងមករៀនទៀងទាត់ៗប៉ុន្តែមានអត្រាបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា ដោយសារបរិយាកាសសិក្សានិងការបង្រៀនមានភាពល្អប្រសើរ។







ថែទាំកុមារឱ្យលូតលាស់ដែលមានសុខភាពល្អតាមរយៈការផ្តល់អាហារូបត្ថម្ភសមស្រប ចំណងជើង : ការសិក្សា នឹងសុខភាពមានទំនាក់ទំនងយ៉ាងជិតស្និតៗ ដើម្បីឱ្យការសិក្សារបស់សិស្សជនជាតិដើមភាគតិចមានភាពល្អប្រសើ វិធានការសុខភាពមួយចំនួនគួរត្រូវបានអនុវត្តន៍ដូចជា៖

ALBERT EINSTEIN

សុខភាពនិងអាហាររូបត្ថម្ភជួយបង្កើនកម្រិតវ័យផ្ចិតរបស់កុមារក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៀនសូត្រជាពិសេសជួយបង្កើនភាពស្ថិតស្ថេររបស់សិស្សក្នុងការសិក្សា។<u>#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល</u>



ក្នុងការអនុវត្តនិងពង្រីកការអប់រំពហុភាសាចាប់ផ្តើមអនុវត្តតាំងតែពី 7 ឆ្នាំមុនហើយមានធនធាននិងបច្ចេកទេសខសៗ គ្នាក្នុងការបង្រៀន យោងទៅតាមខាង មន្ទីរនិងការិយាល័យ អប់រំស្រុក ។ គណៈគ្រប់គ្រងសាលា បាននិយាយថា បញ្ហាហិរញ្ញវត្ថុជាបញ្ហាចម្បងដែលជាកត្តារាំងស្ទះក្នុងការបង្រៀនការអប់រំពហុភាសាដល់សិស្សជនជាតិដើមភាគតិច ។







ការអប់រំមានសារៈសំខាន់ចំពោះការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ យុទ្ធសាស្ត្រការអភិវឌ្ឍន៍របស់ប្រទេសនេះ ផ្តោតការយកចិត្តទុកដាក់លើប្រជាពលរដ្ឋវ័យក្មេង ទាំងការអប់រំ និងសុខភាព ព្រោះពួកគេនឹងក្លាយជាធនធានដ៏សំខាន់ដល់ការអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។

ALBERT EINSTEIN

ការពង្រឹងសមត្ថភាពគ្រូបង្រៀនពហុភាសា ជាវិធានការសំខាន់មួយ ដើម្បីកែលម្អវិស័យអប់រំ និងសម្រួលដល់ការអប់រំរបស់ សិស្សជនជាតិដើមភាគតិច។ ការអប់រំមិនត្រឹមតែបម្រើជាអ្នកប្រឹក្សាប៉ុណ្ណោះទេ ថែមទាំងជាអ្នកតម្រង់ទិសផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនដើរតួច្រើនយ៉ាងក្នុងវិស័យអប់រំ។ ដើរតួជាអ្នកអប់រំ ដើរតួជាអ្នកប្រឹក្សា ថែមទាំងដើរតួជាអ្នកតម្រង់ទិសទៀតផង។



ការអប់រំពហុភាសាពិតជាមានអត្ថប្រយោជន៍ជាច្រើនដែលអាចជួយដល់កុមារជនជាតិដើមភាគតិច ។ ហើយដើម្បីធានានូវភាពជោគជ័យនៃកម្មវិធីអប់រំពហុភាសាគឺពឹងផ្អែកលើការយល់ដឹងពី សហគមន៍និងអាណាព្យាបាលគ្រប់រូបគ្រប់អំពីសារៈប្រយោជន៍នៃកម្មវិធីនេះ។







ដើម្បីឲ្យការសិក្សារបស់កុមារជនជាតិដើមភាគតិចកាន់តែមានភាពងាយស្រួលសាលាអនុវត្តកម្មវិធីពហុភាសារ គួរមានសម្ភារៈប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ដើម្បីអាចជួយដល់សិស្សានុសិស្សជនជាតិដើមភាគតិច ទទួលបានការអប់រំដោយមានប្រសិទ្ធភាពខ្ពស់ ហើយអាចឲ្យពួកគេចូលរួមជាសកម្មសាលាបានកាន់តែច្រើន។

ALBERT EINSTEIN

ការបង្កើតផែនការបង្រៀនតាមស្តង់ដារគឺចាំបាច់សម្រាប់សិស្ស។ វាធានាថាសិស្សានុសិស្សទទួលបានការអប់រំប្រកបដោយគុណភាព។



នៅពេលដែលមិនទាន់មានកម្មវិធីអប់រំពហុភាសាក្មេងៗនៅតាមភូមិមិនចេះនិយាយភាសាខ្មែរទេ។ជាហេតុប្រឈមនឹងការលំបាកច្រើនក្នុងការសិក្សារ ប៉ុន្តែក្រោយពេលមានសាលាបង្រៀនពហុភាសាពួកគេចាប់ផ្ដើមចេះសរសេរ ចេះអានទាំងភាសាកំណើត និងភាសាខ្មែរ ។ កម្មវិធីនេះមិនត្រឹមតែកាត់បន្ថយភាពមិនចេះអក្សរទេ ថែមទាំងជួយកាត់បន្ថយភាពក្រីក្រដល់សហគមន៍ផងដែរតាមរយៈការអភិវឌ្ឍសមត្ថភាពខ្លួនឯង។







ដើម្បីឆ្លើយតបនឹងផែនការជាតិអប់រំ សម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយជាច្រើន ដូចជា គោលនយោបាយសាលាកុមារមេត្រី កម្រិតអប់រំមូលដ្ឋាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងច្បាប់ស្តីពីការអប់រំ។

ALBERT EINSTEIN

#ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
#NEPCambodia



NGO Education Partnership